ឆ្នាំទី១៤ លេខ ៨៧ សប្តាហ៍ទី ៤ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ រាជកិច្ច ទំព័រ ១០៩០៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមការងារអចិន្ត្រៃយ៍ ដើម្បីដោះស្រាយ ជំរុញ និងតាមដានការអភិវឌ្ឍលើកោះរ៉ុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៦៧១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៤ និងមាត្រា១២នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមការងារអចិន្ត្រៃយ៍ដើម្បីដោះស្រាយ ជំរុញ និងតាមដានការអភិវឌ្ឍលើកោះរ៉ុង ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |

| | | |
|---|---|---|
| ២- ឯកឧត្តម **ឈិត សុខុន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម **សុខ ចិន្តាសោភា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- ឯកឧត្តម **ឯល ទ៉ាន់សារ៉ាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៦- ឯកឧត្តម **ប៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- ឯកឧត្តម **ធិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨- ឯកឧត្តម **ប៉ាង ហាមផាន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម **យស់ ឆោមណារ៉ាឌី** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១០- ឯកឧត្តម **ស្តើង សុខុម** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១១- ឯកឧត្តម **ឈោប សាមុត** | អគ្គនាយកនៃអគ្គនាយកដ្ឋានទេសចរណ៍នៃក្រសួងទេសចរណ៍ | សមាជិក |
| ១២- ឯកឧត្តម **សាយ ឬទ្ធិសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៣- ឯកឧត្តម **ឡោ ដាឌុច** | អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤- ឯកឧត្តម **ទ៉ាន់ មុនីនាថ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងបរិស្ថាន | សមាជិក |
| ១៥- ឯកឧត្តម **សូ សុខ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលំនៅឋាន នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៦- លោក **អ៊ឹង ឡូរី** | អនុប្រធានរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក។ |

**មាត្រា២ .-**

ក្រុមការងារអចិន្ត្រៃយ៍ដើម្បីដោះស្រាយ ជំរុញ និងតាមដានការអភិវឌ្ឍលើកោះរ៉ុង មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ដោះស្រាយ ជំរុញ និងតាមដានការអភិវឌ្ឍលើកោះរ៉ុង
- ចាត់វិធានការទប់ស្កាត់និងដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យនៅលើដីចំណីឆ្នេរនិងនៅក្នុងទឹក និងបង្អាក់រាល់ការសាងសង់ដែលពុំមានលិខិតអនុញ្ញាតសាងសង់នៅលើកោះរ៉ុង
- ចាត់វិធានការទប់ស្កាត់និងដោះស្រាយបញ្ហាកាកសំណល់រាវ បញ្ហាកាកសំណល់រឹង និងការទន្ទ្រានដីព្រៃនៅលើកោះរ៉ុង
- ត្រូវអនុវត្តនយោបាយ«ស្បែកខ្លា» ដើម្បីធានាថា ការអភិវឌ្ឍមិនប៉ះពាល់ដល់ការតាំងលំនៅនិងជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន ក្នុងការដោះស្រាយទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋ និងក្រុមហ៊ុនដែលទទួលបានសិទ្ធិវិនិយោគលើកោះរ៉ុង
- ចាត់វិធានការទប់ស្កាត់និងដោះស្រាយបញ្ហាចំពោះមុខនានាដែលធ្វើឱ្យប៉ះពាល់ដល់នគរូបនីយកម្ម បរិស្ថាន និងទេសចរណ៍ ក្នុងគោលបំណងរក្សាឱ្យបាននូវសោភ័ណភាព សណ្តាប់ធ្នាប់ សន្តិសុខសង្គម និងការទាក់ទាញវិស័យទេសចរណ៍បន្ថែមទៀត
- ធ្វើរបាយការណ៍ជាប្រចាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន ជូនគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ធ្វើការបូកសរុបនិងរាយការណ៍ជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៣ .-**

ប្រធានក្រុមការងារអចិន្ត្រៃយ៍ដើម្បីដោះស្រាយ ជំរុញ និងតាមដានការអភិវឌ្ឍលើកោះរ៉ុង អាចស្នើសុំមន្ត្រីពីក្រសួងស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរដែនដីដែលមានតំណាងក្នុងក្រុមការងារអចិន្ត្រៃយ៍នេះ ឱ្យចូលរួមជួយការងាររបស់ក្រុមការងារអចិន្ត្រៃយ៍ តាមការចាំបាច់ និងត្រូវមានការសម្រេចពីរដ្ឋមន្ត្រីនិងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ។

អនុប្រធានអចិន្ត្រៃយ៍ និងសមាជិកនៃក្រុមការងារអចិន្ត្រៃយ៍ដើម្បីដោះស្រាយ ជំរុញ និងតាមដានការអភិវឌ្ឍលើកោះរ៉ុង ត្រូវចូលរួមប្រជុំជាទៀងទាត់ តាមការចាត់ចែងរបស់ប្រធានក្រុមការងារអចិន្ត្រៃយ៍។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តព្រះសីហនុ
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ